**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ២៦៧.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់សហគមន៍ នៃតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ស្ថិតក្នុងភូមិសាស្ត្រស្រុកស្រែអំបិល និងស្រុកបុទុមសាគរ ខេត្តកោះកុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

## សម្រេច

**មាត្រា១៖**

ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង លើផ្ទៃដីចំនួន ៤.៩៥២ ហិកតា(បួនពាន់ ប្រាំបួនរយ ហាសិបពីរហិកតា) ទៅជាតំបន់សហគមន៍ ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកស្រែអំបិល និងស្រុកបុទុមសាគរ ខេត្តកោះកុង។

**មាត្រា២៖**

តំបន់សហគមន៍ ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង មានទីតាំងដូចមានក្នុងផែនទីភ្ជាប់ជាឧបសម្ព័ន្ធ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកាខាងក្រោមៈ

| No | X | Y | No | X | Y |
|---|---|---|---|---|---|
| A | 366110 | 1230732 | M | 344185 | 1237572 |
| B | 363601 | 1229874 | N | 340297 | 1238006 |
| C | 360699 | 1228111 | O | 337806 | 1239082 |
| D | 360914 | 1227519 | P | 335238 | 1239336 |
| E | 361145 | 1225963 | Q | 334785 | 1238883 |
| F | 359874 | 1224204 | R | 335246 | 1237991 |
| G | 360363 | 1223680 | S | 339067 | 1237668 |
| H | 361279 | 1223279 | T | 340508 | 1236812 |
| I | 364048 | 1223004 | U | 342883 | 1236204 |
| J | 366658 | 1226430 | V | 343875 | 1236489 |
| K | 347817 | 1235791 | W | 346900 | 1235320 |
| L | 347114 | 1236537 | | | |

**មាត្រា៣៖**

ការកំណត់តំបន់សហគមន៍ ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ភូមិសាស្ត្រស្រុកស្រែអំបិល និងស្រុកបុទុមសាគរ ខេត្តកោះកុង ជាតំបន់គ្រប់គ្រងបម្រើឲ្យការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់សហគមន៍មូលដ្ឋាន ដែលកំពុងមានសកម្មភាពស្រាប់ រួមមានៈ លំនៅឋាន ស្រែចម្ការ។ រាល់ការចេញប័ណ្ណសម្គាល់ដីធ្លី ឬការអនុញ្ញាតឲ្យប្រើប្រាស់ដីធ្លី នៅក្នុងតំបន់សហគមន៍នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល។

**មាត្រា៤៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
  "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ